លីកាដូ

LICADHO

# សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស  លីកាដូ

# LICADHO

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

ប្រអប់សំបុត្រលេខ ៤៩៩
លីកាដូ: ផ្ទះលេខ ១៦, ផ្លូវ៩៩
សង្កាត់បឹងត្របែក, ខ័ណ្ឌចំការមន
ក្រុងភ្នំពេញ, កម្ពុជា
ទូរសារ: ០២៣ ៣៦០៩៦៥/២១៧៦២៦
គេហទំព័រ: http://www.licadho.org/
អ៊ីម៉ែល:  contact@licadho.org

ថ្ងៃទី១១ ខែមិនា ឆ្នាំ២០០៨

## សេចក្តីប្រកាសព័ត៌មានរបស់អង្គការលីកាដូ
## ការឃុំឃាំងមិនស្របច្បាប់  និងមានការសង្ស័យចំពោះការធ្វើទារុណកម្ម
## ពីសំណាក់ក្រសួងមហាផ្ទៃ

អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ មានការព្រួយបារម្ភជាខ្លាំងអំពីការឃុំឃាំងមិនស្របច្បាប់និងមានការសង្ស័យចំពោះការធ្វើទារុណកម្មទៅលើបុរសម្នាក់នៅកន្លែងឃុំឃាំងរបស់ក្រសួងមហាផ្ទៃ ។

លោក ព្រីង ពៅ ជានគរបាលប្រចាំនៅស្រុកដំណាក់ចង្អើ មកពីសាលាក្រុងកែប ត្រូវបានចាប់ខ្លួនដោយគ្មានដីកាតុលាការ នៅក្រុងកែបកាលពីថ្ងៃទី១៨ ខែកុម្ភៈ ។ បន្ទាប់ពីបញ្ជូនមកដល់ភ្នំពេញនៅថ្ងៃដដែលនោះ លោកត្រូវបានគេឃុំឃាំងរហូតមក អស់រយៈពេលបីសប្តាហ៍ នៅក្នុងអាគារមួយរបស់អង្គភាពនគរបាលអនុវត្តបទបញ្ជា និង នគរបាលអន្តរាគមន៍នៃក្រសួងមហាផ្ទៃ ។ យោងតាមប្រភពព័ត៌មានដែលអាចជឿជាក់បានដែលអង្គការលីកាដូ បានទទួល លោកត្រូវគេវាយដំនិងដាក់ខ្នោះជើងខ្នោះដៃ យ៉ាងតិចណាស់ក៏មួយរយៈពេលនៃពេលវេលាបីសប្តាហ៍ នោះដែរ ហើយបច្ចុប្បន្នលោកមានសុខភាពមិនល្អទេ ។

គេបានរាយការណ៍មកថា លោក ព្រីង ពៅមានពាក់ព័ន្ធក្នុងជំលោះដីធ្លីមួយជាមួយម្ចាស់ក្សត្រីម៉ារី រណឫទ្ធិ ហើយបច្ចុប្បន្ននេះគាត់និងគ្រួសារគាត់កំពុងរស់នៅលើដីនោះនៅឯក្រុងកែប ។

មន្ត្រីនគរបាលមួយចំនួននៃក្រសួងមហាផ្ទៃបានបញ្ជាក់ថា លោក ព្រីង ពៅ កំពុងជាប់ឃុំឃាំងទៅតាមបទបញ្ជាផ្ទាល់របស់លោកឧត្តមសេនីយ៍អគ្គនាយកនគរបាលជាតិ ហុក ឡង់ឌី ។ មន្ត្រីនគរបាលទាំងនោះបានបដិសេធម្តងហើយម្តងទៀត មិនអោយវេជ្ជបណ្ឌិតរបស់អង្គការមិនមែនរដ្ឋាភិបាល និងអ្នកស៊ើបអង្កេតពីអង្គការសិទ្ធិមនុស្សចូលជួបលោក ព្រីង ពៅ នៅកន្លែងឃុំឃាំងឡើយ ដោយនិយាយថា ការអនុញ្ញាតអោយចូលគឺជាការផ្ទុយនឹងបទបញ្ជារបស់លោកឧត្តមសេនីយ៍ ហុក ឡង់ឌី ។

មន្ត្រីមួយចំនួនបានបញ្ជាក់ថា លោក ព្រីង ពៅ ត្រូវគេផ្តល់ការអប់រំវិន័យឡើងវិញ អំពីបទមិនគោរពតាមបញ្ជាថ្នាក់លើក្នុងរឿងជំលោះដីធ្លី ។ អង្គការលីកាដូមិនបានឃើញមូលដ្ឋានច្បាប់ណាមួយដែលអនុញ្ញាតអោយក្រសួងមហាផ្ទៃធ្វើការឃុំឃាំង ឬដាក់ខ្នោះ ឬធ្វើទុក្ខទោសដោយគ្មានភាពប្រាកដប្រជាទៅលើនគរបាលម្នាក់ក្នុងរូបភាពជាការដាក់វិន័យនោះទេ ។ យោងតាមសារាចរស្តីពីការដាក់វិន័យលើកំលាំងនគរបាលជាតិរបស់ក្រសួង

លីកាដូ

# សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

# LICADHO

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

LICADHO

ប្រអប់សំបុត្រលេខ ៤៩៩
លីកាដូ: ផ្ទះលេខ ១៦, ផ្លូវ៩៩
សង្កាត់បឹងត្របែក, ខ័ណ្ឌចំការមន
ក្រុងភ្នំពេញ, កម្ពុជា
ទូរសារ: ០២៣ ៣៦០៩៦៥/២១៧៦២៦
គេហទំព័រ: http://www.licadho.org/
អ៊ីម៉េល: contact@licadho.org

មហាផ្ទៃ ឆ្នាំ១៩៩៥ មន្ត្រីនគរបាលដែលមិនគោរពបញ្ញាអាចទទួលការព្រមាន ស្តីបន្ទោស បន្ថយឋានៈ ឬបណ្តេញចេញពីអង្គភាពនគរបាល ។

យោងតាមច្បាប់នីតិវិធីព្រហ្មទណ្ឌប្រទេសកម្ពុជា ជនសង្ស័យប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដែលនគរបាលចាប់ខ្លួនអាចត្រូវឃុំឃាំងក្នុងរយៈពេលអតិបរមា ៤៨ម៉ោង ដោយមិនចាំបាច់មានការយល់ព្រមពីព្រះរាជអាជ្ញា ។

មន្ត្រីខ្លះបានបញ្ជាក់ច្បាស់ថា លោក ព្រីង ពៅ អាចត្រូវដោះលែង បើសិនជាគាត់ចុះហត្ថលេខាលើឯកសារមួយស្តីពីការយល់ព្រមបោះបង់ការទាមទាររឿងដីនៅក្រុងកែបចោល ។ បើដូច្នេះ បញ្ជាក់អោយឃើញថា គេចាប់គាត់ទុកសំរាប់ជាថ្នូរក្នុងការបង្ខំអោយគ្រួសាររបស់គាត់ចាកចេញពីដីនោះ ។

អង្គការលីកាដូសូមបញ្ជាក់ជូនថា ករណីជំលោះដីធ្លីទាំងអស់សូមមេត្តាដោះស្រាយតាមរយៈការស៊ើបអង្កេត ឯករាជ្យនិងត្រឹមត្រូវដែលធ្វើឡើងដោយស្ថាប័នតុលាការ និងស្ថាប័នពាក់ព័ន្ធរបស់រដ្ឋ ដោយអាស្រ័យច្បាប់ត្រឹមត្រូវ ។ ចំពោះករណីមួយនេះ បើមិនចាំបាច់គិតដល់ថា នណាជាម្ចាស់កម្មសិទ្ធិដីស្របច្បាប់នោះ ប៉ុន្តែមានការអនុវត្តខុសនីតិវិធីក្នុងការចាប់ខ្លួន និងការឃុំខ្លួនដោយមិនស្របច្បាប់រួចទៅហើយ ។

អង្គការ លីកាដូ សូមស្នើដោយទទូចសូមមេត្តាអោយមានការដោះលែង លោក ព្រីង ពៅ ពីកន្លែងឃុំឃាំងនៃក្រសួងមហាផ្ទៃអោយបានឆាប់ ពីព្រោះលោកត្រូវបានឃុំឃាំងដោយមិនស្របច្បាប់ ។ បើសិនជា លោកមិនត្រូវបានដោះលែងភ្លាម១ទេ យ៉ាងតិចណាស់ សូមក្រសួងមហាផ្ទៃមេត្តាអនុញ្ញាតអោយវេជ្ជបណ្ឌិតរបស់អង្គការមិនមែនរដ្ឋាភិបាល មានឱកាសចូលជួបជាមួយគាត់អោយបានឆាប់ ដើម្បីអោយប្រាកដថា គាត់បានទទួលការថែទាំវេជ្ជសាស្ត្រគ្រប់គ្រាន់ ។

ព័តិមានបន្ថែម សូមទំនាក់ទំនង:

កញ្ញា **ណាលី ពីឡូក** នាយិកាអង្គការលីកាដូ ០១២ ៨០៣ ៦៥០